ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៤ លេខ ១២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC

កសវ



# Work Activities

ប្រចាំខែធ្នូ ឆ្នាំ២០១១



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | ទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត | ១ |
| ២- | សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា | ៣ |
| ៣- | សេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១១ស្តីពីការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ | ៤ |
| ៤- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែតុលា ឆ្នាំ២០១១ | ៦ |
| ៥- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៤ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត



កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង៨:៣០ នាទីនិងម៉ោង១៥:០០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើក អង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **យូឃាង ថាវរិទ្ធ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **អ៊ុំ ប៊ុនធឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត** ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងទេសចរណ៍។

ដោយអនុលោមតាមស្មារតីនៃមាត្រា៩នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត និងដើម្បីសម្រួលដល់ការដាក់ឲ្យដំណើរការចលនាប្រឡងប្រណាំងទីក្រុងស្អាតប្រកបដោយប្រសិទ្ធភាពគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតដែលមានគោលបំណងដូចខាងក្រោម៖

- ជំរុញការរៀបចំចលនាប្រលងប្រណាំងទីក្រុងស្អាតក្នុងទិសដៅជំរុញការលើកកម្ពស់សោភ័ណភាព អនាម័យ ស្អាត និងមជ្ឈដ្ឋានរស់នៅល្អប្រសើរនៅតាមបណ្តាទីក្រុងឲ្យកាន់តែមានប្រសិទ្ធភាព។
- ជាសេនាធិការឲ្យ គ.ជ.វ.ទ. ក្នុងការវាយតម្លៃលើទីក្រុង (ដោយផ្អែកលើស្តង់ដារទីក្រុងស្អាត) ដែលនឹងផ្តល់លទ្ធភាពឲ្យទីក្រុងបេក្ខភាពក្លាយជាគោលដៅទេសចរណ៍ដែលអាចទាក់ទាញការមកទស្សនាកាន់តែច្រើនឡើងពិសេសជំរុញការគិតគូរដល់ភាពស្អាតមានអនាម័យនិងមជ្ឈដ្ឋានរស់នៅល្អប្រសើរនៅតាមទីក្រុង។
- ដើម្បីជំរុញដល់ការការពារ ថែរក្សា និងអភិរក្សបរិស្ថាននៅទីក្រុងនីមួយៗនៃព្រះរាជាណាចក្រកម្ពុជា។




ជាការពិត ការរៀបចំសេចក្តីព្រាងអនុក្រឹត្យនេះ ដើម្បីចូលរួមទ្រទ្រង់តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការជាតិ គ.ជ.វ.ទ. ក្នុងការជំរុញនិងសម្រួលដល់ចលនាប្រឡងប្រណាំងទីក្រុងស្អាត ព្រមទាំងលើកកម្ពស់សោភ័ណភាព អនាម័យល្អ សុវត្ថិភាព និងបរិស្ថានល្អនៅតាមបណ្តាទីក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយចលនានេះក៏ត្រូវបានចាត់ទុកជាផ្នែកអាទិភាពមួយក្នុងយុទ្ធសាស្ត្រអភិវឌ្ឍទេសចរណ៍កម្ពុជា សំដៅធ្វើឲ្យកម្ពុជាក្លាយជាគោលដៅបៃតងប្រកបដោយគុណភាពស្តង់ដារពិភពលោកនិងចូលរួមចំណែកបន្ថែមទៀតក្នុងការជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត ដែលជាចលនាមួយអាចធ្វើឲ្យប្រសើរឡើងនូវបរិស្ថាន គុណភាពសេវាកម្មនៅតាមបណ្តាទីក្រុងនៅព្រះរាជាណាចក្រកម្ពុជា រួមចំណែកដល់ការធ្វើឲ្យប្រសើរឡើងនូវកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងជាពិសេសទាក់ទាញទេសចរឲ្យមកទស្សនាកម្ពុជាកាន់តែច្រើនថែមទៀត(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែ សម្រួល ទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះ កាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង៕

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត។

## សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី

# ការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិង អភិវឌ្ឍឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា



កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង ៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **យូឃាង ថាវរិទ្ធ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ជីវ សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា** ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រកម្ពុជាដែលជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍនៅតាមឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ប្រកបដោយនិរន្តរភាពនិងការទទួលខុសត្រូវ ដើម្បីទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន វប្បធម៌ និងប្រពៃណីក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជា។

ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានដាក់បញ្ចូលជាសមាជិកក្លឹបឆ្នេរស្អាតបំផុតលើពិភពលោក កាលពី ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ នៅប្រទេសសេណេហ្គាល់កន្លងមកនេះ។ ក្នុងឱកាសពិធីអបអរសាទរការដាក់បញ្ចូលឆ្នេរសមុទ្រកម្ពុជាជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកនៅខេត្តព្រះសីហនុ កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ កន្លងមកនេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ឲ្យបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដោយមានប្រសាសន៍ថា “ គណៈកម្មការអន្តរក្រសួងដើម្បីដាក់បញ្ចូលឆ្នេរសមុទ្រកម្ពុជាជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតជាងគេបំផុតលើសកលលោក ត្រូវជំរុញរៀបចំបង្កើតគណៈកម្មាធិការជាតិអភិវឌ្ឍនិងគ្រប់គ្រងឆ្នេរសមុទ្រកម្ពុជាឲ្យបានឆាប់រហ័ស ដើម្បីជាយន្តការរួមមួយក្នុងការគ្រប់គ្រងការអភិវឌ្ឍ និងការអភិរក្សឆ្នេរសមុទ្រកម្ពុជា ដោយគ្របដណ្តប់លើទិដ្ឋភាពរួមទាំងផ្នែក នគរូបនីយកម្ម បរិស្ថាន និងទេសចរណ៍...”(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងនេះ ហើយបានសម្រេចកែ សម្រួល ទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះ កាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង៕

---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រព្រះរាជាណាចក្រកម្ពុជា។

## សេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១១ស្តីពី

# ការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម២០០៩-២០១៣

កាលពីថ្ងៃទី២០ ថ្ងៃទី២១ ថ្ងៃទី២២ ថ្ងៃទី២៧ និងថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង៨:៣០នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម **កែវ ចិចិត្រ** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) និង ឯកឧត្តម **ផៃ សុខខេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១១ស្តីពីការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក អគ្គលេខាធិការរង និងមន្ត្រីនៃក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញនៃទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងផែនការ។

ដោយផ្អែកតាមខ្លឹមសារនៃជំពូកទី៦ នៃផែនការយុទ្ធសាស្រ្ត(ផ.យ.អ.ជ.)បច្ចុប្បន្នកម្ម២០០៩-២០១៣ ផែនការនេះចាំបាច់ត្រូវធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃ តាមរយៈការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំនិងរបាយការណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ។

ដំណើរការនៃការរៀបចំឯកសារនេះ បានត្រូវបានចាប់ផ្តើមជាជំហានៗតាំងពីដើមឆ្នាំនេះមកម្លេះ ដោយក្រសួងផែនការបានធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ នៅក្នុងការងារជាមូលដ្ឋានចំនួនពីរ ទី១គឺការពិគ្រោះពិភាក្សាលើការកែសម្រួលសូចនាករស្នូលសម្រាប់ការតាមដានត្រួតពិនិត្យ ការអនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម និងទី២គឺការណែនាំអំពីធាតុចូល។



របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ នេះត្រូវបានរៀបចំឡើង ដោយមានកិច្ចពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយនឹងបណ្តាក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាលកម្ពុជាដែលអនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម។ របាយការណ៍នេះបានធ្វើការវាយតម្លៃចេញពីមូលដ្ឋានមួយចំនួនដូចខាងក្រោម៖

- របាយការណ៍ដែលត្រូវបានរៀបចំឡើងដោយក្រសួង ស្ថាប័ន នានារបស់រាជរដ្ឋាភិបាលកម្ពុជា




- ការពិគ្រោះយោបល់ជាមួយនឹងក្រសួង ស្ថាប័ន ចំនួន៤២
- ការពិគ្រោះយោបល់ជាមួយនឹងដៃគូអភិវឌ្ឍន៍នានា តាមរយៈយន្តការក្រុមការងារបច្ចេកទេស
- ការពិនិត្យឡើងវិញពីទិន្នន័យថ្មីៗ ជាពិសេស ទិន្នន័យពីជំរឿនទូទៅនូវប្រជារាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០០៤ ឆ្នាំ២០០៧ ឆ្នាំ២០០៨ និងឆ្នាំ២០០៩។ លទ្ធផលបណ្ដោះអាសន្ននៃជំរឿនសហគ្រាសឆ្នាំ២០១០និងទិន្នន័យមូលដ្ឋានឃុំ សង្កាត់(ប្រចាំឆ្នាំ ដែលមានរហូតដល់ឆ្នាំ២០១០)
- ការពិនិត្យមើលឡើងវិញពីការសិក្សាស្រាវជ្រាវជាលក្ខណៈគោលនយោបាយមួយចំនួនដែលពាក់ព័ន្ធនឹងឯកសារគោលនយោបាយថ្មីៗមួយចំនួនរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្រៅពីការវិភាគលើព័ត៌មានផ្នែកបរិមាណនិងលើចំណុចដៅនានាក្នុង ផ.យ.អ.ជ. បច្ចុប្បន្នកម្ម របាយការណ៍នេះនឹងបង្ហាញផងដែរពីបញ្ហាទាំងឡាយដែលកើតមាននៅក្នុងការអនុវត្តផែនការនិងការគាំទ្រទាំងឡាយដែលចាំបាច់សម្រាប់ធ្វើឲ្យសម្រេចបាននូវចំណុចដៅនានារបស់ផែនការ(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្ដីព្រាងនេះ ហើយបានសម្រេចកែ សម្រួល ទម្រង់ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគ ដើម្បីធ្វើឲ្យសេចក្ដីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្ដីព្រាងនេះទាំងស្រុង៕

(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុនៃសេចក្ដីព្រាងរបាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០១១ស្ដីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែតុលា ឆ្នាំ២០១១*



របាយការណ៍ស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែតុលា ឆ្នាំ២០១១នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ដែលដឹកនាំដោយ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្ដូរប្រាក់

➡ នាខែតុលានេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កើនឡើង ០,១% ធៀបនឹងខែមុន និងកើនឡើង ៥,៣% បើធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។ កំណើនសន្ទស្សន៍ថ្លៃខែតុលា/កញ្ញា មានក្រុមម្ហូបអាហាររួមចំណែករហូតដល់ ១៧១%។ នៅក្នុងក្រុមម្ហូបអាហារ គួរកត់សម្គាល់ការកើនឡើងខ្ពស់នៃថ្លៃ អង្ករ និងបន្លែ ដែលមានអត្រារួមចំណែក ៤១៣% និង ៣០៣% រៀងគ្នា ទៅលើកំណើនសន្ទស្សន៍ថ្លៃសរុប ។

➡ ក្រុមទំនិញដែលគួរឲ្យចាប់អារម្មណ៍មានបម្រែបម្រួលសន្ទស្សន៍ថ្លៃដូចខាងក្រោម៖

| ប្រភេទ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ | ប្រភេទ | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|---|---|
| ម្ហូបអាហារ | +០,២% | +៦,២% | ភោជនីយដ្ឋាន | −០,១% | +៦,៨% |
| ការដឹកជញ្ជូន | −០,៧% | +៧,៣% | | | |

* ការវិភាគជាលាយលក្ខណ៍អក្សរជាការដកស្រង់ចេញពីទិន្នន័យចម្បងៗប៉ុណ្ណោះ មិនគ្របដណ្ដប់តួលេខទាំងអស់នៃតារាងទាំង៥ទេ។ ដូច្នេះ អ្នកប្រើប្រាស់ទិន្នន័យអាចទាញយកតួលេខពីតារាងតាមសេចក្ដីត្រូវការរៀងខ្លួន។
* ព័ត៌មាន និងតួលេខពណ៌បៃតងសំដៅលទ្ធផលល្អប្រសើរ និងពណ៌ក្រហមសំដៅលទ្ធផលសម្រាប់ការថ្លឹងថ្លែង។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងបរទេស សញ្ញាក្បៀសនៅក្នុងអត្ថបទសំណេរតាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (ជា Excel ) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

### តារាង១.បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០០៩ - ២០១១

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា[P] | ធ្នូ[P] | ប្រចាំឆ្នាំ[P] |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៩% | ៥,៧% | ៦,២% |
| | ខែមុន | ០,២% | ០,៧% | ០,៧% | ១,១% | ១,៤% | ០,៥% | ០,៦% | ០,២% | ១,០% | ០,១% | -០,៩% | -០,៨% | |
| ២០១០ | ខែដូចគ្នាឆ្នាំមុន | ៦,៩% | ៧,៣% | ៦,៧% | ៥,៣% | ៤,៥% | ២,៥% | ១,៦% | ១,៧% | ១,៩% | ៣,៦% | ៣,២% | ៧,៣% | ៤% |
| | ខែមុន | ០% | ០,៣% | ០,៦% | -០,៣% | ០,២% | ០% | ០,៥% | ០,៩% | ០,៧% | ១,៤% | –១,០% | –០,២% | |
| ២០០៩ | ខែដូចគ្នាឆ្នាំមុន | ៨,០% | ៦,២% | -០,៧% | -៣,៩% | -៥,៧% | -៤,៨% | -៣,៩% | -២,៩% | -២,៣% | -១,៥% | ១,៣% | ៨,០% | -០,៧% |
| | ខែមុន | -១,៥% | -០,១% | ១,៣% | ១,០% | ១,០% | ១,៩% | ១,៤% | ០,៧% | ០,៥% | -០,៣% | -០,៦% | -០,១% | |

P: តួលេខខែ វិច្ឆិកា ធ្នូ និងប្រចាំឆ្នាំ ២០១១ ជាតួលេខព្យាកររបស់ក.ស.វ. ( តាមវិធីសាស្ត្រ DECOMPOSITION )

### ក្រាហ្វ ១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ឆ្នាំ ២០១០ និង ២០១១ (ធៀបនឹងខែដូចគ្នាឆ្នាំមុន)




ក្រាហ្វ១ បង្ហាញនិន្នាការបម្រែបម្រួលសន្ទស្សន៍ថ្លៃ (ធៀបនឹងខែដូចគ្នា) ឆ្នាំ ២០១០ និង ២០១១។ក្រាហ្វនេះក៏បង្ហាញផងដែរ នូវតួលេខការព្យាករពីរខែទៅមុខនៃអត្រាអតិផរណា (ធៀបនឹងខែដូចគ្នាឆ្នាំមុន)។

➡ អត្រាប្តូរប្រាក់៖

| *ប្រភេទ* | អត្រាខែតុលា ២០១១ | អត្រាខែវិច្ឆិកា ២០១១ | អត្រាខែតុលា ២០១០ | *ប្រភេទ* | អត្រាខែតុលា ២០១១ | អត្រាខែវិច្ឆិកា ២០១១ | អត្រាខែតុលា ២០១០ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤១០០៛/១$ | ៤០៨០៛/១$ | ៤២២២៛/១$ | **បាត/ដុល្លារ** | ៣១,១៧បាត/១$ | ៣០,៤៧បាត/១$ | ២៩,៩៦បាត/១$ |
| **៛/បាត** | ១៣៤៛/១បាត | ១៣១៛/១បាត | ១៤១៛/១បាត | **ដុង/ដុល្លារ** | ២០៩៨៦ ដុង/១$ | ២០៧៨៥ ដុង/១$ | ១៩៥០០ ដុង/១$ |
| **៛/ដុង** | ០,១៩៥៛/១ដុង | ០,១៩៥៛/១ដុង | ០,២១៧៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡ យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ**នាខែតុលា ឆ្នាំ២០១១ ថវិកាជាតិ**មានស្ថានភាពដូចខាងក្រោម៖

↳ ***ចំណូលថវិកាជាតិអនុវត្តបានចំនួន ៤៨៣,៥ ពាន់លានរៀល*** *(មធ្យមប្រចាំខែ ៨៩% នៃគម្រោង)* *ក្នុងនោះ* ***ចំណូលមូលធន ១,៧ ពាន់លានរៀល*** (*មធ្យមប្រចាំខែ ៧៨% នៃគម្រោង*) និង **ចំណូលចរន្ត ៤៨១,៨ ពាន់លានរៀល** (មធ្យមប្រចាំខែ ៩០% នៃគម្រោង)។

↳ បើធៀបនឹងខែមុន **ចំណូលថវិកាជាតិ** កើនឡើង ១% និងកើនឡើង ១៣% *បើធៀបនឹងខែដូចគ្នាឆ្នាំមុន*។ ការកើនឡើងនៃចំណូលក្នុងរយៈពេល១២ខែ ដូច្នេះបណ្តាលមកពីកំណើន នៃចំណូលចរន្ត ១៧% ។

### ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១០ និង ២០១១



- នៅក្នុងចំណូលចរន្ត៖
  - ✓ ចំណូលសារពើពន្ធ ថយចុះ ១% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៥% ក្នុងរយៈពេល១២ខែ ក្នុងនោះ៖
    - ➢ ពន្ធ និងអាករគយ កើនឡើង ៣% បើធៀបនឹងខែមុន និងកើនឡើង ២២% ក្នុងរយៈពេល១២ខែ

✧គួរចាប់អារម្មណ៍ថា អាករបន្ថែមលើផលិតផលគេលសិលាថយចុះ ៣% ធៀបនឹងខែមុន និងថយចុះ ១% បើធៀបនឹងខែដូចគ្នាឆ្នាំមុន ។

- ➢ ចំណូលពន្ធដារ ថយចុះ ៩% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៣% ក្នុងរយៈពេល១២ខែ
- ✓ ចំណូលមិនមែនសារពើពន្ធកើនឡើង ២៩% បើធៀបនឹងខែមុន និងថយចុះ ១៧% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

| ក្នុងចំណូលសារពើពន្ធ (ក្នុងវង់ក្រចកៈ បម្រែបម្រួលរយៈពេល១២ខែ) | | ក្នុងចំណូលមិនមែនសារពើពន្ធ (ក្នុងវង់ក្រចកៈ បម្រែបម្រួលរយៈពេល១២ខែ) | |
|---|---|---|---|
| ➢ ពន្ធ-អាករគយៈ +៣% | ( +២២%) | ➢ នេសាទ : +៨៩៨% | (+៣៣៨%) |
| ➢ ចំណូលពន្ធដារៈ -៩% | (+២៣%) | ➢ រុក្ខាប្រមាញ់ : +៣២% | (+១១៦%) |
| ➢ ចំណូលសារពើពន្ធផ្សេងៗៈ -១១% | (-២២%) | ➢ អាកាសចរណ៍ស៊ីវិល : +១០០% | (+៨២%) |
| ✧ កាស៊ីណូ : -១៨% | (+២៣%) | ➢ ផលទុនទេសចរណ៍ : -៤៨% | (+៣៨%) |
| ✧ អាជ្ញាបណ្ណក្នុងស្រុក : 0 | (-៤%) | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ : +៥៤% | (+១៤៥%) |
| ✧ គ្រប់គ្រង និងទិដ្ឋាការនាំចេញ : -៥% | (-៤១%) | ➢ អាករស្ថានទូត (លិខិតឆ្លងដែននិងទិដ្ឋាការ) : +២៥% | (+១១៩%) |

***ចំណាយថវិកាជាតិ***អនុវត្តបាន ៤១០ ពាន់លានរៀល (*មធ្យមប្រចាំខែ ៦៧% នៃគម្រោង*) ក្នុងនោះ **ចំណាយចរន្ត**មានចំនួន ៣៤៧ ពាន់លានរៀល (*មធ្យមប្រចាំខែ ១០០% នៃគម្រោង*) និង**ចំណាយមូលធន**មានចំនួន ៦២ ពាន់លានរៀល(*មធ្យមប្រចាំខែ ២៧% នៃគម្រោង*) ។

*បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ**ថយចុះ ៣៥% ប៉ុន្តែកើនឡើង ១៥% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការថយចុះនៃចំណាយថវិកាជាតិ ក្នុងខែនេះ ជាចំបងបណ្តាលមកពីចំណាយចរន្តថយចុះ ២៨% ប៉ុន្តែបើធៀបនឹងខែដូចគ្នាឆ្នាំមុន ចំណាយចរន្ត កើនឡើង ៣៣% ។

*តុល្យភាពថវិកាជាតិនៃខែតុលាមានអតិរេក ៧៤ ពាន់លានរៀល*។

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ ស្ថានភាពរូបិយវត្ថុ ក្នុងខែតុលា ឆ្នាំ ២០១១ មានលក្ខណៈដូចខាងក្រោម៖

**រូបិយវត្ថុ** M ₂ មាន **២២ ៦៤០** ពាន់លានរៀល ថយចុះ:0,១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៧% ក្នុងរយៈពេល១២ខែ។

**ការថយចុះតិចតួចនៃ M ₂** ធៀបនឹងខែមុន បណ្តាលមកពី រូបិយវត្ថុក្រៅធនាគារ ថយចុះ ៣,៤% និងប្រាក់បញ្ញើជារូបិយប័ណ្ណ ថយចុះ 0,១% ។

យោងតាមតួលេខសមាសធាតុរូបិយវត្ថុ ក្នុងខែនេះ ប្រាក់រៀលសរុប**ក្នុងសេដ្ឋកិច្ច**មានចំនួន ១៨,៤% នៃរូបិយវត្ថុ M ₂ និងប្រាក់បញ្ញើជារូបិយបណ្ណ មានចំនួន ៨១,៦%។

ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុ ខែតុលា ២០១១



| សមាមាត្រ រវាងចំនួនប្រាក់រៀល និងការផ្គត់ផ្គង់រូបិយវត្ថុ $M_2$ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុប នៅក្នុង និងក្រៅធនាគារ | ១៨,៣% | ១៩,១% | ១៩,២% | ១៩,១% | ១៨,៥% | ១៨,០% | ១៧,៦% | ១៧,៨% | ១៨,៤% | ១៨,៤% | | |
| ប្រាក់រៀលក្រៅធនាគារ | ១៥,៧% | ១៦,០% | ១៦,៧% | ១៦,៦% | ១៥,៧% | ១៥,២% | ១៤,៩% | ១៤,៩% | ១៥,៦% | ១៥,១% | | |

## បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែ តុលា ២០១១ : ក្នុងវង់ក្រចកជា បម្រែបម្រួលរយៈពេល១២ខែ




➥ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន **២ ៩១៦លានដុល្លារ** កើនឡើង ៣,៩% បើធៀបនឹងខែមុន និងកើនឡើង ១៩% ក្នុង រយៈពេល១២ខែ។

➥ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ជារួម មានការប្រែប្រួលមិនទៀងទាត់។ ក្នុងខែនេះ មានចំនួន **៧ ០៩៣ ពាន់លានរៀល** ថយចុះ ២% បើធៀបនឹងខែមុន និងថយចុះ ៤% ក្នុងរយៈពេល១២ខែ។

➥ ***ការផ្តល់ឥណទានដោយធនាគារពាណិជ្ជ*** ជារួម មានការកើនឡើង។ ក្នុងខែនេះ មានចំនួន ១៦ ៧៤៥ ពាន់លានរៀល កើនឡើង ២% បើធៀបនឹងខែមុន និងកើនឡើង ៣២% ក្នុងរយៈពេល១២ខែ។

➥ ***ការផ្តល់ឥណទានដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ*** មាននិន្នាការកើនឡើង ឯក្នុងខែនេះមានចំនួន **២៤២២ ពាន់លានរៀល** កើនឡើង ៤,១% បើធៀបនឹងខែមុន និងកើនឡើង ៤៥% ក្នុងរយៈពេល១២ខែ។

➥ ***អត្រាការប្រាក់ប្រចាំឆ្នាំ នាខែតុលា៖***

| *ប្រភេទអត្រាការប្រាក់* | *អត្រា* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| ▪ បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៥២% | 0% | –១% |
| ▪ កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៩,០៨% | +២២% | –១៦% |
| ▪ បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,២៦% | -៣,៦% | -៣% |
| ▪ កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១៤,៨៦% | 0% | –៨% |

## ៤) ស្ថានភាពកសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ ក្នុងខែតុលា ឆ្នាំ២០១១ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➥ **កសិកម្ម៖**

✓ ផលិតកម្មនេសាទមាន **៤៥ ពាន់តោន** កើនឡើង ១៨% បើធៀបនឹងខែមុន និងកើនឡើង ៤១% ក្នុងរយៈពេល១២ខែ។

## ឧស្សាហកម្ម៖

- ✓ ថាមពលអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមាន **២២៧ ជីកាវ៉ាត់ម៉ោង(GWh)** កើនឡើង ៦% បើធៀបនឹងខែមុន និង កើនឡើង ២១% ក្នុងរយៈពេល១២ខែ។
- ✓ អគ្គិសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមាន **៨,៨ ជីកាវ៉ាត់ម៉ោង(GWh)** ថយចុះ ២% បើធៀបនឹងខែមុន និងកើនឡើង ៩% ក្នុងរយៈពេល១២ខែ។
- ✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមាន ៤១៧ លានដុល្លារ កើនឡើង ៥% បើធៀបនឹងខែមុន និងកើនឡើង ២៩% ក្នុងរយៈពេល១២ខែ។
- ✓ ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាសនៅក្រសួងឧស្សាហកម្ម៖

| *ប្រភេទ* | *ចំនួន —តុលា២០១១* | *ចំនួន—កញ្ញា២០១១* | *ចំនួន—តុលា២០១០* |
|---|---|---|---|
| ▪ រោងចក្រថ្មី ដែលបានចុះបញ្ជី | ៩ | ១៥ | ៨ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១៥ | ១៥ | ១៥ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ១៦ | ១៥ | ២៦ |

## សំណង់៖

✓ **សំណង់អនុញ្ញាតឲ្យសាងសង់**ក្នុងខែតុលា មានចំនួន ៤១២ ពាន់ម$^2$ ថយចុះ ១% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១២៤% ក្នុងរយៈពេល១២ខែ។ បើគិតជាទឹកប្រាក់ ការអនុញ្ញាតឲ្យសាងសង់មានតម្លៃ ១១០ លានដុល្លារ ថយចុះ ៧% បើធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៣១% ក្នុងរយៈពេល១២ខែ។

✓ **សំណង់ដែលពេញនិយម** យោងតាមតួលេខអនុញ្ញាតនាខែនេះ គឺសំណង់ឧស្សាហកម្ម (៦១% នៃផ្ទៃក្រឡាអនុញ្ញាតសរុប) និងលំនៅឋាន( ៣២% នៃផ្ទៃក្រឡាអនុញ្ញាតសរុប)។

| *ប្រភេទ* | *ផ្ទៃក្រលា ពាន់ម$^2$ —តុលា២០១១* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| ▪ លំនៅឋាន | ១៣២ | +៣% | -១០% |
| ▪ ឧស្សាហកម្ម | ២៥១ | +១៦% | +៤៧៣០% |
| ▪ ពាណិជ្ជកម្ម | ៥ | -៧៣% | -២៣% |
| ▪ ទេសចរណ៍ | ៨ | -២៧% | +២៤៧% |

## ការងារ៖

| *ប្រភេទ* | *ចំនួន—តុលា២០១១* | *%Δ ធៀបនឹងខែមុន* | *%Δ រយៈពេល១២ខែ* |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ៣ ៥០០ | +៣៤% | +៩% |
| *អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន* | ៤ ៥៧១ | +៥៨% | –៣៤% |
| អ្នកទទួលបានការងារក្នុងប្រទេស | ២ ២៣៦ | +១២២% | –៣៦% |
| អ្នកទទួលបានការងារក្រៅប្រទេស | ២ ៣៣៥ | +២៤% | –៣១% |

## វិនិយោគ៖

✓ គម្រោងវិនិយោគ**អនុញ្ញាតដោយ** គ.វ.ក./គ.អ.ក. (ថ្មីនិងពង្រីក) ក្នុងខែតុលា មានចំនួន **១៥** ដែលគិតជាទុន វិនិយោគស្មើនឹង **៣៤៤លានដុល្លារ** ។ គម្រោងទាំងនេះអាចបង្កើតការងារឲ្យពលករបាន **២៤ ពាន់នាក់**។

| *ប្រភេទ* | *តុលា២០១១* | *កញ្ញា២០១១* | *តុលា២០១០* |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៣៤៤ | ១៤១ | ១១៥ |
| វិស័យកសិកម្ម និង កសិឧស្សាហកម្ម | ២ | ២៧ | ២២ |
| វិស័យឧស្សាហកម្ម | ៩៧ | ៥៦ | ១៨ |
| វិស័យទេសចរណ៍ | ២៤៥ | ៥៨ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធ និង ផ្សេងៗ | ០ | ០ | ៧៥ |
| **ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន)** | ១៥ | ១៧ | ៨ |
| **ចំនួនពលករ (ពាន់នាក់)** | ២៤ | ១៧ | ៦ |

➢ **សេវាកម្ម និងទេសចរណ៍៖**

✓**ការចុះបញ្ជី និងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម**

| ប្រភេទ | ចំនួន – តុលា២០១១ | ចំនួន – កញ្ញា២០១១ | ចំនួន–តុលា២០១០ |
|---|---|---|---|
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៨៦ | ២១៧ | ២៦៧ |
| ▪ ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៥ | ៤ | ៣ |
| ▪ ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ២១៨ | ២៥២ | ១៩៨ |

✓ **ទំនិញឆ្លងកាត់កំពង់ផែ** (សរុប៦កំពង់ផែ) មានចំនួន ៣៩២ ពាន់តោន កើនឡើង ១០% ធៀបនឹងខែមុន និងកើនឡើង ២៣% ក្នុងរយៈពេល១២ខែ ក្នុងនោះ៖

| ក្នុងវង់ក្រចកៈ បម្រែបម្រួលក្នុងរយៈពេល១២ខែ | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ : +៥% | (+២៤%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង : +៤៤% | (+១១២៣%) |
| ▪ កំពង់ផែកំពង់សោម : +៦% | (+0,៤%) | ▪ កំពង់ផែឧកញ៉ាម៉ុង : 0 | (-៣១%) |

➢ **ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖**

| ប្រភេទ | ចំនួន (ពាន់នាក់) | %Δ ធៀបនឹងខែមុន | %Δ រយៈពេល១២ខែ |
|---|---|---|---|
| ▪ ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ៤,៤ | -២៩% | +៧% |
| ▪ អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ២៧៤ | +១២% | +៩% |
| ▪ ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៦៤ | -១៧% | +២៩% |
| ▪ ចំនួនទេសចរអន្តរជាតិមកដល់ព្រះរាជាណាចក្រកម្ពុជា | ២៣៣ | +១១% | +១៣% |
| ✓ តាមផ្លូវអាកាស | ១១៩ | +២៥% | +១០% |
| ✓ តាមផ្លូវគោក និងទឹក | ១១៤ | -១% | +១៧% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ **ការនាំចូល**នាខែតុលាមានចំនួន ២ ២៩៤ ពាន់លានរៀល បើធៀបនឹងខែមុន កើនឡើង ១៦% និងកើនឡើង ៤៧% ក្នុងរយៈពេល១២ខែ ក្នុងនោះ៖

| ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ១២ខែ | ទំនិញ | %Δ ធៀបនឹងខែមុន | %Δ ១២ខែ |
|---|---|---|---|---|---|
| ប្រេងសាំង | +៥% | +៨% | ម៉ូតូ (គ្រឿង) | –៣% | +១% |
| ឧស្ម័ន | +១៤% | +២៦% | ប្រេងម៉ាស៊ូត | –៥% | –១% |
| គ្រឿងអេឡិចត្រូនិក | +៦៩% | +១១៥% | ប្រេងខ្មៅ | –៤៥% | –៥៥% |
| ការនាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៣១% | +២៤% | ដែកសំណង់ | –៣៧% | +៧៤% |
| រថយន្តសរុប (ព.ល.រ) | –៥% | +៣៩% | ស៊ីម៉ង់ត៍ | –៦% | +១៤% |
| រថយន្តសរុប (គ្រឿង) | –១០% | +២៦% | ជីនិងថ្នាំកសិកម្ម | –២៣% | +៤៤% |
| ត្រាក់ទ័រនិងគោយន្ត (គ្រឿង) | –៤៨% | –៤៩% | | | |

➡ **ការនាំចេញ** ក្នុងខែតុលា ឆ្នាំ២០១១ មាននួន ១ ៦៤៨ ពាន់លានរៀល (៧២% នៃការនាំចូល) ថយចុះ ១៤% ធៀបនឹង ខែមុន ប៉ុន្តែកើនឡើង ៨% ក្នុងរយៈពេល១២ខែ ក្នុងនោះ មុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δ ១២ខែ | ទំនិញ | %Δធៀបនឹងខែមុន | %Δ ១២ខែ |
|---|---|---|---|---|---|
| ផលិតផលនេសាទ | -២២% | +១១% | ផលិតផលឈើកែច្នៃ | -៩៧% | -៩៧% |
| អង្ករ | -២៧% | +១៩៣% | វាយនភណ្ឌនិងស្បែកជើង | -១៦% | +៣% |
| កៅស៊ូ | 0 | +៨០% | | | |

➡ ក្នុងខែតុលានេះ ជញ្ជីងពាណិជ្ជកម្មមាន *ឱនភាពចំនួន ៦៤៦ ពាន់លានរៀល ស្មើនឹង ១៥៧ លានដុល្លារ ស.រ.អ.។*

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែតុលា ឆ្នាំ២០១១នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ. | សូចនាករ | ធៀបនឹងខែមុន | រយៈពេល១២ខែ | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | កម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំចេញ | -៥% | -៤១% | ជាប្រភេទចំណូលថវិកាជាតិ នៅក្នុង"ចំណូលសារពើពន្ធផ្សេងៗ" |
| ២ | អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | 0 | -២៨% | នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ "**អម្រឹត**" អត្រាការប្រាក់កម្ចីជារៀល ថយចុះពី ៣៩% ក្នុងខែតុលា ឆ្នាំ២០១០ មកនៅត្រឹម ២៨,២% ក្នុងខែតុលា ឆ្នាំ២០១១។ នេះជាកត្តាវិជ្ជមាន ដែលបង្ហាញពីនិន្នាការថយចុះនៃអត្រាការប្រាក់កម្ចីរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។ |
| ៣ | ការនាំចេញអង្ករ | +២៧% | +១៩៣% | — |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

១) ក្នុងខែតុលា បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់មានកម្រិតទាបសមរម្យ : +0,១% បើធៀបនឹងខែមុន និង ៥,៣% បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ យ៉ាងណាក្តី យើងសង្កេតឃើញថា ក្នុងទំនិញប្រើប្រាស់ខែនេះ អង្ករនិងបន្លែបង្ហាញការឡើងថ្លៃគួរឲ្យចាប់អារម្មណ៍។

យោងតាមគួលេខព្យាករ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ខែវិច្ឆិកានិងធ្នូ ឆ្នាំ២០១១ នឹងមានការថយចុះ ធៀបទៅនឹងខែមុន និងអតិផរណាប្រចាំ ២០១១ (កំណើនសន្ទស្សន៍ថ្លៃមធ្យម) មានកម្រិត ៦,២% ។

២) ចំណូលពន្ធអចលនទ្រព្យ ក្នុងឆ្នាំដំបូង ២០១១នេះ បានចំនួនប្រហែលជាង ៥លានដុល្លារ ស.ហ.អា ។ ដំណើរការប្រមូលពន្ធអចលនទ្រព្យក្នុងឆ្នាំទី១នេះ បន្សល់នូវបទពិសោធន៍អំពីនិតិវិធីបង់ពន្ធដែលត្រូវកែសម្រួលនាឆ្នាំក្រោយៗ និងនូវការក្តាប់បានព័ត៌មានមួយចំនួន ដូចជាផ្ទៃដីទុកទំនេរប៉ុន្តែមានតម្លៃខ្ពស់ដែលត្រូវជាប់ពន្ធជាដើម។ ចំណូលពន្ធអចលនទ្រព្យ ដែលប្រមូលបាននាឆ្នាំនេះ មានចំនួនលើសពីការរំពឹងទុករបស់អគ្គនាយកដ្ឋានពន្ធដារ។

៣) ដោយសារការប្រកួតប្រជែង អត្រាការប្រាក់នៅកម្ពុជាមាននិន្នាការថយចុះបណ្តើរៗ ក៏ប៉ុន្តែគម្លាតរវាងអត្រាការប្រាក់បញ្ញើ និងអត្រាការប្រាក់កម្ចីនៅតែធំ។

*ក.ស.វ. មានសេចក្តីសន្និដ្ឋានដូចខាងក្រោម៖*

ការកើនឡើងនៃតម្រូវការលើម្ហូបអាហារជាសាកល ជាឱកាសល្អសម្រាប់ប្រទេសកសិកម្ម ដូចជាកម្ពុជា។ កសិកម្មគឺជាវិស័យអាទិភាពសម្រាប់កម្ពុជា ក្នុងការបង្កើតបរិយាកាសវិនិយោគ ការគៀរគរវិនិយោគ និងជំរុញការនាំចេញផលិតផលកសិកម្ម។

តម្រូវការអង្ករខ្ពស់នៅលើទីផ្សារអន្តរជាតិ និងមហិច្ឆតានាំចេញ របស់ប្រទេសផលិតអង្ករ នឹងធ្វើឲ្យថ្លៃអង្ករមានកម្រិតខ្ពស់ ក្នុងប្រទេសនាំអង្ករចេញ៕



**សេចក្តីកែតម្រូវ**

ក្នុងរបាយការណ៍ខែមុន ក.ស.វ បានលាតត្រដាងការពិភាក្សានៃកិច្ចប្រជុំអំពីតម្រូវការសាច់ជ្រូក នៅរាជធានីភ្នំពេញ មានចំនួនប្រហែល ២០តោន ឬជាង ២០០ក្បាល ក្នុងមួយថ្ងៃ។

សម្រាប់ភាពសុក្រឹត សូមកែតម្រូវថា "ទីក្រុងភ្នំពេញមួយកន្លែង មានតម្រូវការសាច់ជ្រូកប្រមាណ ២៣,២តោន ក្នុងមួយថ្ងៃ"។

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/១២/១១<br>ម៉ោង ០៩ : ០០ នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យជាចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។<br>៣-បញ្ហាផ្សេងៗ។<br>នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០១/១២/១១<br>ម៉ោង ១៥ : ០០ នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការបច្ចេកទេស ក្រុមការងារជំនាញវប្បធម៌ និងក្រុមការងារជំនាញស្ថាបត្យកម្ម និងសំណង់ ដើម្បីសម្របសម្រួលការអនុវត្តគម្រោងវិនិយោគសាងសង់អគារសារមន្ទីរសព្វទស្សន៍ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ០៥/១២/១១<br>ម៉ោង ០៨ : ០០ នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកវេទិកាជាតិស្តីពី ការផ្សព្វផ្សាយយុទ្ធសាស្រ្តជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៤ | ០៦/១២/១១<br>ម៉ោង ០៨ : ៣០ នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែតុលា ឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៩/១២/១១<br>ម៉ោង ០៨ : ៣០ នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។<br>៣-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិលើ " សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រង ការប្រើប្រាស់ហត្ថពលកម្មនៅរដ្ឋកាតា រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋកាតា "។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |
| ៦ | ១០/១២/១១<br>ម៉ោង ០៨ : ០០ នាទី | ដឹកនាំក្រុមការងារគណៈកម្មការព្រលានយន្តហោះត្រួតពិនិត្យផ្លូវហោះហើរព្រលានយន្តហោះខេត្តព្រះសីហនុ ។ |

## សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១១

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | **១៤/១២/១១ ម៉ោង** ០៧:៣០នាទី " | ចូលរួមជាកិត្តិយសក្នុងពិធីប្រគល់សញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ណជ័យលាភីអាហារូបករណ៍ សម្តេចតេជោ ហ៊ុន សែន ហាន់ដា ចក្ខុវិស័យ ១០០ ឆ្នាំ ២០១១ ជូនដល់និស្សិតសាកលវិទ្យាល័យ កម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៨ | **១៥/១២/១១ ម៉ោង** ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីបើកកិច្ចប្រជុំលើកទី១៧ រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន កិច្ចប្រជុំលើកទី១០ រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន-ចិន កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន-ជប៉ុន កិច្ចប្រជុំលើកទី៣ រដ្ឋមន្ត្រីដឹកជញ្ជូនអាស៊ាន-សាធារណរដ្ឋកូរ៉េ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៩ | **១៦/១២/១១ ម៉ោង** ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យ និងតាមដានការបង់ចំណូលថវិកាជាតិ និងការអនុវត្តកិច្ចព្រមព្រៀងវិនិយោគរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះសូស៊ីយេតេ កុងសេស្យូនែរ ដឺឡាអេរ៉ូព័រ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | **១៧/១២/១១ ម៉ោង** ០៨:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសំណេះសំណាលជាមួយកាយរឹទ្ធិជាតិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា ជាគរុគណនៃ កាយរឹទ្ធិជាតិកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ១១ | **១៩/១២/១១ ម៉ោង** ១៥:០០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធជើងហោះហើរ រវាងខេត្តសៀមរាប និងខេត្តព្រះសីហនុ របស់ ក្រុមហ៊ុនអាកាសចរណ៍ជាតិ កម្ពុជា អង្គរ អ៊ែរ និងពិធីជប់លៀង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ និងសណ្ឋាគារឆ្នេរសុខា។ |
| ១២ | **២១/១២/១១ ម៉ោង** ០៨:៣០នាទី | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសអនុវត្តក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

# សកម្មភាពផ្សេងទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១១ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៣ | **២១/១២/១១ ម៉ោង ១៤:៣០នាទី** " | ចូលរួមជាកិត្តិយសក្នុងពិធីបិទមហោស្រពសិល្បៈចម្រៀងខ្មែរសកលក្រោមអធិបតីភាពរបស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៌កោះពេជ្រ។ |
| ១៤ | **២២/១២/១១ ម៉ោង ១៥:00 នាទី** | ចូលរួមប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១៥ | **២៨/១២/១១ ម៉ោង ១៥:00 នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការត្រួតពិនិត្យ និងតាមដានការបង់ចំណូលចូលថវិកាជាតិរបស់ក្រុមហ៊ុន SCA នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | **២៩/១២/១១ ម៉ោង ០៨:៣០ នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១១ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៧ | **២៩/១២/១១ ម៉ោង ១២:៣០ នាទី** | ចូលរួមពិសារអាហារថ្ងៃត្រង់ជាមួយលោក COTTIN ឯកអគ្គរាជទូតសហភាពអឺរ៉ុប នៅរាជធានីភ្នំពេញ។ |
| ១៨ | **២៩/១២/១១ ម៉ោង ១៥:៣០ នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការសាងសង់អគារមិត្តភាព គណៈកម្មការថែទាំអគារទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមហ៊ុនសាងសង់វិស្វកម្មយូណាន នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

# សកម្មភាពដទៃទៀតរបស់ ឯកឧត្តម អនុប្រធាន និង សមាជិក-សមាជិកា ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែធ្នូ ឆ្នាំ២០១១

## ឯកឧត្តម យឹម ណុលសន អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៥/១២/១១ | ចូលរួមជាកិត្តិយសក្នុងពិធីបើកវេទិកាជាតិស្តីពីការផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះនៅកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ២ | ១០/១២/១១ | ចូលរួមជាកិត្តិយសក្នុងពិធីដាក់ឲ្យប្រើប្រាស់អគារសាលប្រជុំ និងការិយាល័យ ព្រមទាំងសមិទ្ធិផលនានារបស់កងរាជអាវុធហត្ថខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីរួមខេត្តតាកែវ។ |
| ៣ | ២១/១២/១១ | ចូលរួមជាកិត្តិយសក្នុងពិធីប្រកាសអនុវត្តក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៤ | ២១/១២/១១ | ចូលរួមជាកិត្តិយសក្នុងពិធីបិទមហោស្រពសិល្បៈចម្រៀងខ្មែរសកលក្រោមអធិបតីភាពរបស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងលោកជំទាវ ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |

## ឯកឧត្តម ម៉ាន់ ភិរុណ អនុប្រធាន

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៩/១២/១១ | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ។<br>៣-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិ ប្បញ្ញត្តិលើ " សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការគ្រប់ គ្រង ការប្រើប្រាស់ហត្ថពលកម្មនៅរដ្ឋកាតា រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃ រដ្ឋកាតា "។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី ។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ ៖ | ឯកឧត្តម [illegible] | អនុប្រធាន គ.ស.វ. |
| និពន្ធនាយក ៖ | ឯកឧត្តម [illegible] | អគ្គលេខាធិការ គ.ស.វ. |
| និពន្ធអក្ខបទ ៖ | ឯកឧត្តម [illegible] | អគ្គលេខាធិការរង គ.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច ៖ | ឯកឧត្តម [illegible] | សមាជិកបម្រុង គ.ស.វ. |
| បច្ចេកទេសកុំព្យូទ័រ និងសម្របសម្រួល ៖ | លោក [illegible] | ប្រធានការិយាល័យ គ.ស.វ. |
| យកព័ត៌មាន និងថតរូប ៖ | លោក [illegible] | មន្ត្រី គ.ស.វ. |
| ទំនាក់ទំនង និងបោះពុម្ពផ្សាយ ៖ | លោក [illegible] | ជំនួយការទេសរដ្ឋមន្ត្រីប្រធាន គ.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in